# សេចក្តីប្រកាសព័ត៌មាន

## ទិន្នន័យមជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់បានបង្ហាញឱ្យឃើញថា អំពើពុករលួយក្នុងស្ថាប័នតុលាការ ស្ថាប័នប៉ូលិស និងស្ថាប័នសាធារណៈគឺជាការព្រួយបារម្ភដ៏ចម្បងរបស់ជនរងគ្រោះនិងសាក្សីនៃអំពើពុករលួយ

***រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៧*** - *នៅថ្ងៃនេះ មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់ នៃអង្គការតម្លាភាពកម្ពុជា* (TI Cambodia) *បានចុះផ្សាយទិន្នន័យចុងក្រោយរបស់ខ្លួនអំពីចំនួនករណីដែលមជ្ឈមណ្ឌលបានផ្តល់ការប្រឹក្សាយោបល់ជូនជនរងគ្រោះ និងសាក្សីនៃអំពើពុករលួយនៅក្នុងប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់បានទទួលករណីសរុបចំនួន ១៩១ ទាក់ទងនឹងអំពើពុករលួយ ។ ករណីជាច្រើនដែលត្រូវបានរាយការណ៍ មានទម្រង់ជាអំពើពុករលួយខុសៗគ្នា ដែលកើតឡើងក្នុងវិស័យធំៗចំនួន ៥ គឺ៖*

- *វិស័យសាធារណៈ*
- *តម្លៃសេវាសាធារណៈ*
- *តុលាការ*
- *ប៉ូលិស*
- *វិស័យអប់រំ ។*

*ទិន្នន័យបានបង្ហាញឱ្យដឹងថាទម្រង់នៃអំពើពុករលួយដែលបានកើតឡើងជាទូទៅ រួមមានការជំរិតទារប្រាក់* (*៤១*%) *ការសូកប៉ាន់* (*៣៨*%) *និងការកេងប្រវ័ញ្ចថវិកា ឬការបោកប្រាស់* (*១៦*%) *។ ស្ថាប័នតុលាការ ស្ថាប័នប៉ូលីស និងស្ថាប័នសាធារណៈ នៅតែជាស្ថាប័នដែលមានកំរិតអំពើពុករលួយខ្ពស់បំផុតក្នុងប្រទេសកម្ពុជា ។*

ចាប់តាំងពីការចាប់ដំណើរការនៅចុងឆ្នាំ ២០១៣ រហូតមកដល់បច្ចុប្បន្ននេះ មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់ បានផ្តល់ការប្រឹក្សាផ្នែកច្បាប់ជូនទៅប្រជាពលរដ្ឋកម្ពុជានិងជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ចំនួន ៥៤៧នាក់ ទោះបីជាប្រទេសកម្ពុជានៅមិនទាន់មានច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ក៏ដោយ ។ មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់ ជារឿយៗក៏ផ្តល់ព័ត៌មានទូទៅទាក់ទងនឹងតម្លៃសេវាសាធារណៈផងដែរ។

លោក ព្រាប កុល នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍ថាៈ «ទិន្នន័យរបស់មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់នេះ ឆ្លុះបញ្ចាំងពីសម្លេង និងការព្រួយបារម្ភណ៍ពិតប្រាកដ របស់ជនរងគ្រោះនៃអំពើពុករលួយ ។ របកគំហើញនេះ បានគូសបញ្ជាក់សារជាថ្មីថាអំពើពុករលួយក្នុងប្រព័ន្ធយុត្តិធម៌ ប៉ូលិស និងវិស័យសាធារណៈនៅតែបង្កផលប៉ះពាល់ ដល់ប្រជាពលរដ្ឋទូទៅ និងនៅតែជាឧបសគ្គដ៏ធំបំផុតដល់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ យើងខ្ញុំសូមជម្រុញឱ្យរដ្ឋាភិបាល និងស្ថាប័នដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយទាំងអស់ ធ្វើកំណែទម្រង់ប្រកបដោយឆន្ទៈ នៅក្នុងវិស័យទាំងនេះ និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយឲ្យកាន់តែមានប្រសិទ្ធភាព»។

ដើម្បីបង្កើតបរិយាកាសអំណោយផលទៅនឹងការរាយការណ៍ដែលមានលក្ខណៈទូលំទូលាយជាងនេះ អង្គការតម្លាភាពកម្ពុជាសូមជម្រុញឱ្យមានការអនុម័តច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ ដែលអនុលោមតាមស្តង់ដាអន្តរជាតិ។

**អំពីមជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់**

មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់នៃអង្គការតម្លាភាពកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៣ គឺជាផ្នែកមួយនៃគម្រោងជាសកលរបស់អង្គការតម្លាភាព

អន្តរជាតិ ដែលមានវត្តមាននៅតាមសាខានៅជាង១០០ប្រទេសទូទាំងសកលលោក។ មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្តល់យោបល់ផ្នែកច្បាប់ជាសម្ងាត់ និងមិនគិតថ្លៃជូនសាក្សី និងជនរងគ្រោះនៃអំពើពុករលួយ ដោយផ្តល់ជូនយន្តការគួរឲ្យទុកចិត្ត និងអាចសំរេចបាន សំរាប់ប្រជាពលរដ្ឋក្នុងការដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើពុករលួយ។ មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្តល់សិទ្ធិអំណាចទៅប្រជាពលរដ្ឋដើម្បីចាត់វិធានការក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ មជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់ ក៏ដើរតួយ៉ាងសំខាន់ក្នុងការកំណត់កន្លែងដែលមានអំពើពុករលួយ ដែលទាមទារឲ្យមានកំណែទម្រង់ ឬវិធានការផ្លូវការ។ ដោយផ្អែកលើទិន្នន័យពិតប្រាកដ និងមានឥទ្ធិពលទទួលបានដោយមជ្ឈមណ្ឌលតស៊ូមតិ និងប្រឹក្សាយោបល់ផ្នែកច្បាប់ អំពីលទ្ធផល និងយន្តការនៃការប្រព្រឹត្តអំពើពុករលួយ អង្គការតម្លាភាពកម្ពុជា ចងក្រងគ្រប់របាយការណ៍ទាំងអស់ដើម្បីចូលរួមក្នុងការតស៊ូមតិជាយុទ្ធសាស្រ្តដែលនាំមកនូវការផ្លាស់ប្តូរវិជ្ជមាន។

អង្គការតម្លាភាពកម្ពុជា ប្តេជាចូលរួមជាមួយរដ្ឋាភិបាល និងគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការឆ្ពោះទៅក្នុងកំណែទំរង់ជាបន្ត និងដើម្បីគាំទ្រអោយមានតម្លាភាព សុច្ចរិតភាព គណនេយ្យភាព និងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យដោយនិរន្តរភាពប្រសើរជាងមុននៅក្នុងប្រទេសកម្ពុជា។

*អង្គការតម្លាភាពអន្តរជាតិគឺជាអង្គការសង្គមស៊ីវិលឈានមុខក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ*

**ពត៌មានទំនាក់ទំនងសំរាប់ស្ថាប័នផ្សព្វផ្សាយ**

លោក ព្រាប កុល នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា (+855) 12 877 833)
kolpreap@ticambodia.org